# ការបង្ខាំងអ្នកជំងឺ

## Applying Restraints



បង្រៀនដោយៈ លោក យឹម សុវណ្ណារ៉ា MHA BScN

ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៤

# គោលបំណង

នៅចុងបញ្ចប់នៃមេរៀននេះ និស្សិតនឹងអាច៖

- ដឹងពីនិយមន័យនៃការបង្ខាំងអ្នកជំងឺ
- ដឹងពីទស្សនៈទូទៅនៃការបង្ខាំងអ្នកជំងឺ
- ស្គាល់ឧបករណ៍ចាំបាច់មួយចំនួនសម្រាប់បង្ខាំងអ្នកជំងឺ
- ចេះពីរបៀបថែទាំអ្នកជំងឺដែលមានតម្រូវការបង្ខាំង

# និយមន័យ

ការបង្ខាំងអ្នកជំងឺ

- ជាឧបករណ៍ វិធីសាស្រ្ត ឬដំណើរការ ដែលគេប្រើសម្រាប់គោលបំណងដើម្បី កម្រិតសកម្មភាព ឬចលនារបស់អ្នកជំងឺ ដែលមិនបានអនុញ្ញាត



# ប្រភេទនៃការបង្ខាំង

ការបង្ខាំងអ្នកជំងឺមាន៣ប្រភេទ៖

1. ការបង្ខាំងផ្នែករាងកាយ(Physical Restraints): កម្រិតការធ្វើចលនារបស់អ្នកជំងឺ
2. ការបង្ខាំងដោយសារធាតុគីមី (Chemical Restraints): ជាប្រភេទការប្រើប្រាស់ថ្នាំរំងាប់អារម្មណ៍ដែលមិនមែនជាការព្យាបាលជំងឺទេ តែក្នុងគោលបំណងបង្អាក់ចលនា ឬឥរិយាបទមិនសមស្រប
3. ការបង្ខាំងផ្នែកបរិស្ថាន (Environmental Restraints): ដើម្បីគ្រប់គ្រងការចល័តរបស់អ្នកជំងឺ

# ទស្សនៈទូទៅ

- ការបង្ខាំងអ្នកជំងឺក្នុងគោលបំណងឱ្យគាត់មានសុវត្ថភាព តែអាចបណ្តាលឱ្យប៉ះពាល់ផ្លូវអារម្មណ៍ សិទ្ធិបុគ្គល និងសេចក្តីថ្លៃថ្នូររបស់គាត់ផងដែរ
- សមាគមន៍គិលានុបដ្ឋាកអាមេរិកាំង (ANA) បានបង្កើតសេចក្តីណែនាំមួយដែលមានចំណងជើងថា " restraint-free environment is the standard of care"
- ANA ជម្រុញឱ្យមានការចូលរួមពីគិលានុបដ្ឋាក/ឆ្មបក្នុងការកាត់បន្ថយការបង្ខាំងអ្នកជំងឺ
- ទោះជាយ៉ាងណាក៏ដោយ ANA បានទទួលស្គាល់ថាការបង្ខាំងអ្នកជំងឺត្រូវតែធ្វើក្នុងករណីមិនមានជម្រើ ដូចជា អ្នកជំងឺរើរវាយ មានអាការដូចកម្រោលចូល (Aggression) ឬការវាយតប់ (Assault)
- កត់ត្រាឱ្យបានត្រឹមត្រូវ និងមានសាក្សីបញ្ជាក់ផងដែរ ក្នុងករណីចាំបាច់ដែលត្រូវតែធ្វើការបង្ខាំង

# គោលបំណងចម្បងក្នុងការបង្ខាំងអ្នកជំងឺ

- បង្ការសុវត្ថិភាពដល់អ្នកជំងឺ និងអ្នកដទៃទៀតភ្លាមៗ
- ការពារអ្នកជំងឺពីការធ្លាក់
- បង្ការអ្នកជំងឺពីការបង្អាក់ក្នុងការព្យាបាល
- ការពារកុំឱ្យគាត់បោច ឬដកឧបករណ៍ផ្សេងៗសម្រាប់ជួយសង្គ្រោះជីវិតគាត់
- កាត់បន្ថយហានិភ័យដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ

# ប្រភេទនៃឧបករណ៍បង្ខាំងអ្នកជំងឺ

| TYPES | INDICATIONS | IMAGES |
|---|---|---|
| 1.MITTENS RESTRAINTS | •Patient who scratch themselves or pull out tubes. |  |
| 2. LAP OR BELT IN THE CHAIR | •Patients at risk of sliding or falling form the chair. |  |

# ប្រភេទនៃឧបករណ៍បង្ខាំងអ្នកជំងឺ

| | | |
|---|---|---|
| 3. BED RAIL OR SIDE RAILS | •Patient at risk of fallings. |  |
| 4. CHAIR WITH BELT | •Patient at risk of wandering or falling. |  |
| 5. ABDOMINAL BELT | •Patients at risk of falling or self-harm. |  |

# ប្រភេទនៃឧបករណ៍បង្ខាំងអ្នកជំងឺ

| | | |
|---|---|---|
| 6.WRIST RESTRAINT | •Patient at risk of pulling out the tubes. |  |
| 7. ELBOW RESTRAINT | •Patients at risk of pulling out the tubes. |  |
| 8.MUMMY RESTRAINT | •To restrict the movement of the limb in small children during procedures. |  |

# ហានិភ័យគ្រោះថ្នាក់នៃការបង្ខាំងអ្នកជំងឺ

- ខូចជាលិកាកន្លែងបង្ខាំង
- ខូចផ្នែកខ្លះនៃរាងកាយ ឧ.បង្ខាំងកន្លែងកែងដៃអាចមានវិបត្តិចលនា
- អាចមានដំបៅគ្រែ
- ប្រឈមនឹងការកើតជំងឺរលាកសួតដោយសារការបឺតស្រូប (Aspiration Pneumonia)
- អ្នកជំងឺមានអារម្មណ៍ថាគាត់ដូចត្រូវបានរងពិន័យ

# របៀបថែទាំនៃការបង្ខាំងអ្នកជំងឺ

- ពន្យល់ពីតម្រូវការនៃការបង្ខាំង
- ពិចារណាលើអារម្មណ៍របស់ក្រុមគ្រួសារអ្នកជំងឺ
- ការបង្ខាំងអ្នកជំងឺមិនអាចធ្វើឡើងដោយគ្មានវេជ្ជបញ្ជាឡើយ
- ត្រូវតែមានកិច្ចសន្យា និងការយល់ព្រមពីអ្នកជំងឺ ឬក្រុមគ្រួសារគាត់
- ត្រូវធ្វើការតាមដាន និងថែទាំអ្នកជំងឺបង្ខាំងដោយយកចិត្តទុកដាក់បំផុត

# របៀបថែទាំនៃការបង្ខាំងអ្នកជំងឺ(គ)

- ត្រូវប្រាកដថាកន្លែងបង្ខាំងមិនមានប៉ះពាល់ដល់ចលនាឈាមរត់
- ទ្រាប់កន្លែងដែលមានឆ្អឹងពយ
- បន្ធូរ យ៉ាងហោចណាស់រៀងរាល់៤ម៉ោងម្តង
- ឧស្សាហ៍ទៅមើលគាត់រៀងរាល់៣០នាទីទៅ១ម៉ោងម្តង

# កិច្ចការផ្ទះ (Assignment)

- ចូរធ្វើការសិក្សាស្រាវជ្រាវទៅលើទម្រង់ការនៃការថែទាំនៃការបង្ខាំងអ្នកជំងឺ (Nursing Procedure on Applying Restraints)
- ផុតកំណត់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

# សូមអរគុណ!